ប្រុសស្អាតនិយាយពាក្យនោះហើយក្រោកមកប្រឈមមុខនឹងខ្ញុំកៀកៗគ្នា។

មិញនេះគេថាគេក៏អម្បូរឆ្កែចចក? ស្តាប់ខុស? ជាថ្មីម្តងទៀត គេខ្សឹបមកកែវភ្នែកខ្ញុំ៖

«នៅក្នុងប្រពៃណី Ojibwe មនុស្សម្នាក់ៗជាកម្មសិទ្ធិរបស់ត្រកូលមួយ! យើងមានតំណពូជដែលបានមកតាមរយៈហ្សែនឪពុក»

«រឿងព្រេងនិទានកថាមែនទេ!»

«មិនមែន! ជាការពិតមានលើលោកនេះ! យើងជាបុព្វការីនៃសត្វឬធាតុមនុស្សឬទាំងពីរយ៉ាងចូលគ្នាឬជាបិសាចទៀតក៏មាន!»

«បាន....»

«ព្រោះហាន់នីមិនដឹង បានជាចង់ប្រាប់!»

ខ្ញុំនៅស្ងៀមចាញ់ស្នូរដង្ហើមគេនេះ ក្លិនប្រុសលើខ្លួនគេ និងភាពឆក់ទាញបេះដូង។ គេនិយាយបន្ត៖

«នោះគឺ.....ត្រកូលយើងដែលជំនាន់ក្រោយណាក៏ត្រូវដាក់ឈ្មោះតាម! ដូច្នេះ ទោះបីជាយើងស្រឡាញ់គ្នាប៉ុនណា អូនសម្លាញ់ជាមនុស្ស ខ្ញុំជាក្រុមចចក ពួកយើងជាឈាមដែលប្រកែកគ្នាបដិសេធគ្នា យើងមិនអាចរៀបការបានទេ»។

ខ្ញុំនិយាយទាំងស្លូតតែលួចខូចចិត្ត៖

«កាន់តែវែងហើយ!»

បបូរមាត់របស់គេញ័រៗ ចំហខ្លះបិទខ្លះ ប្រហែលជាមិនបានកំពុងលេងសើចជាមួយខ្ញុំទេ។ ខ្ញុំដកដង្ហើមធំ។ យើងមានរឿងអីត្រូវរៀបការនឹងគ្នាប្រុសអាក្រាត? គេចូលមករឹតតែជិត។ ខ្ញុំចូលចិត្តរង្វង់លំហផ្ទាល់ខ្លួនរបស់ខ្ញុំ ដែលពេលនេះគេកំពុងលុកលុយទម្លាយ។

ខ្ញុំថយបន្តិចធ្វើមុខធម្មតា តែក៏មានន័យថាខ្ញុំភ័យណាស់ខ្លាចគេមកប៉ះពាល់ខ្ញុំ។

ខ្ញុំគិត តែមុខខ្ញុំប្រហែលចេញសញ្ញាក្រហមឱ្យគេដឹងចិត្ត។

«ម្យ៉ាងទៀត ខ្ញុំចង់ឱ្យហាន់នីជឿថា មានសមាជិកត្រកូលចចក ដែលបានវិវត្តមកពីសត្វចចក ពួកយើងមានអំណាចនិងមានអ្វីដែលមនុស្ស១០០ភាគរយមិនមាន»

«គួរឱ្យចាប់អារម្មណ៍! តែវាចម្លែកបន្តិចហើយសម្រាប់ខ្ញុំ!» ខ្ញុំងាកមុខគេចពីកែវភ្នែកគេ ដែលពេលនិយាយប្រាកដម្ដងៗ ពិតជាមុតដូចម្រឹគ។ ចិត្តខ្ញុំជ្រួលច្រាលណាស់ខ្ញុំបន្ថែម៖

«ព្រេងនិទាននេះខ្ញុំបានអានកាលពីក្មេង!»

គេគ្រវីក្បាល៖

«អត់ទេជេស៊ី! ដឹងថា អ្នកណាជាម្ចាស់ស្លាករូបចចកនេះដែរ?»

«ឥឡូវនេះមិនទាន់ទេ តែមុនក្រោយខ្ញុំនឹងរកឃើញគេ!»

«បងព្រមានអូនស្រីស្អាត នេះមិនមែនជាស្លាកនៃត្រកូលចចកធម្មតាទេ! មួយវិញទៀត ទុកឱ្យខ្ញុំ ទុកវានៅនឹងខ្ញុំ ដើម្បីខ្ញុំអាចសិក្សាជ្រៅបន្តិចសិនបានដែរ?»

«ហេតុអ្វី?»

មានការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សក្នុងកាយវិការរបស់គេ។ គេមានអាការៈភ័យរំជួលចិត្ត លាក់កំបាំងនៅក្នុងប្រធានបទដែលយើងកំពុងតែបានបន្តនិយាយគ្នា។ Will នេះបានធ្វើឱ្យខ្ញុំងឿងឆ្ងល់ឡើងជានិច្ចហើយ។

«ជាន័យនៃវិញ្ញាណចចកដែលខ្លាំងក្លានិងសាហាវ!»

ខ្ញុំញញឹមចំអក។ គេនៅតែខំមកពន្យល់៖

«រឿងព្រេងនិទានអាចកើតមាន ព្រោះពួកគេបានជួបហេតុការណ៍ពិតនិងបន្តមកក៏និទានតៗគ្នា! អ្វីៗទាំងអស់នៅក្នុងរឿង មាននៅក្នុងលោកនេះ ហើយអាណាចក្រនោះកំពុងតែមានជីវិតបន្តជាមួយមនុស្សលើផែនដី!»

ខ្ញុំងក់ក្បាលសើច ព្រោះចង់បញ្ចប់ការស្ដាប់ប្រយោគអស់នេះ។

គេងក់ក្បាលដែរ ប្រហែលជាដឹងថាខ្ញុំមានៈមិនស្ដាប់។ គេនិយាយ៖

«ពេលណាមួយស្រីស្អាតនឹងយល់!»

«ហ៊ឹម មិនដឹងហេតុអីខ្ញុំខំមករកលោក! ដើម្បីអីទៅ? លោកមិនមានព័ត៌មានអីទាំងអស់ Will»

«មាន!»

«ស្អីគេ?» ខ្ញុំអៀនសម្លក់ហើយញញឹមពេញចិត្តការញ៉ែគ្នានេះ។

«មានរបស់ធំៗ» គេញញឹមសម្លក់ខ្ញុំ។

«ខួរក្បាល?»

«បាទ របស់ផ្សេងអូន!»

ខ្ញុំចង់និយាយបន្លប់តែចាញ់គេពេកហើយ រកនឹកពាក្យបន្លប់មិនបានទេក៏វាយស្មាគេផូង។ គេនិយាយខ្សឹបមកទៀត៖

«ផ្ដល់ឱកាសឱ្យខ្ញុំបង្ហាញវាចេញមក និងទេពកោសល្យពិសេសរបស់វាទេ!»

ខ្ញុំបែរខ្នងចេញ គេស្រែកតាមមក៖

«កុំរត់ មិនមែនទាំងថ្ងៃអ៊ីចឹងទេហាន់នី!»

«កុំសង្ឃឹម!» ខ្ញុំស្រែកបែរខ្នង «ហើយ....ប្រាប់ខ្ញុំផងបើរកឃើញតម្រុយអ្វីមួយជុំវិញស្លាកនេះ!»

បានន័យថាខ្ញុំព្រមជួបគេទៀត ហើយព្រមផ្ញើរបស់នេះក្នុងដៃគេ។

«ខ្ញុំនឹងទាក់ទងទៅស្រីស្អាត! Jessie»

របៀបដែលគេនិយាយឈ្មោះខ្ញុំនេះ ធ្វើឱ្យខ្ញុំនឹកឃើញពីភាពស្រស់ស្អាតនៃស្បែកអាក្រាតរបស់គេឡើងវិញនៅក្នុងរង្វង់ពន្លឺព្រះចន្ទទឹកប្រាក់។ សាច់ដុំណែនៗរបស់គេនិងក្រវិលមាសបក់រវិចៗ។

តើពេលណាទៅដែលខ្ញុំបានរួមភេទចុងក្រោយបង្អស់? យូរពេកហើយ ខ្ញុំមិននឹកឃើញសោះ។ មិនដឹង ពេលណា ស្ទើរតែមិនចាំផងថា ជាមួយអ្នកណា។ មិនមែនមានដៃគូច្រើនទេ តែបេះដូងនេះ Format ចេញអស់អតីតហើយ។ មកតាមផ្លូវ ខ្ញុំស្អប់ចិត្តអារាត់អារាយមួយនេះ។ ខ្ញុំត្រូវចាំថា Will Cadotte ខ្ញុំមករកមុននេះ ត្រឹមជាអ្នកប្រឹក្សាជំនាញបុរាណវត្ថុ ក្រៅពីនេះ ពួកយើងគ្មានអ្វីទៀតនោះទេ ហេតុអ្វីខ្ញុំគិតដល់ការស្រមៃវែងហួសព្រោះចាញ់ការញ៉ែរបស់គេ?

នេះជារឿងល្ងង់ខ្លៅមួយលាក់កំបាំងក្នុងខ្លួនខ្ញុំ។ ចិត្តខ្ញុំទៅជាមនុស្សស្រីល្មោភស្នេហ៍ម្នាក់ លែងជាប៉ូលិសពិតត្រឹមពេលឃើញគេ។ ខ្ញុំនៅតែស្រមៃមកអន្លើៗ ចង់ទទួលអារម្មណ៍ដឹង ថាបាតដៃធំៗនិងគ្រើមៗទាំងនោះ ពេលពាល់មកស្បែករបស់ខ្ញុំតើអ្វីនឹងកើតឡើង? ឈាមខ្ញុំរត់ល្អជាងឥឡូវនេះដែរទេ?

សេចក្ដីវេទនាខ្លោចផ្សាព្រោះឯកា និងការដែលចង់បានដៃថ្នមប្រលោម បាននៅនឹងខ្ញុំជិតមួយទសវត្សមកហើយ។ ខ្ញុំធ្លាប់មានមិត្តភក្ដិប្រុសៗ ប៉ុន្តែខ្ញុំមិនដែលឱ្យអ្នកណាម្នាក់មានឱកាសមកជិត

ស្និទ្ធពេកដូចប៉ុនេះទេព្រោះកាលមុន ធ្លាប់មានស្នេហាម្ដងរួចមកហើយតាំងពីរៀនវិទ្យាល័យ ក្រោយមក ទំនាក់ទំនងនោះត្រូវបានបញ្ចប់យ៉ាងដំណំចិត្ត។ ប្រហែលកាលហ្នឹងខ្ញុំចង់បានពេក ផ្ដេកផ្ដួលនិងរំពឹងលើដៃគូពេក បានជាពេលដែលគ្មានគេ ខ្ញុំស្លាប់ទាំងដកដង្ហើម។

ក្រោយមកខ្ញុំបានរកឃើញខ្លួនឯង ថាខ្ញុំជានរណា។ ប៉ូលិសល្អម្នាក់ ឯការរស់យប់ក៏រស់បាន។ អត់អីទេ!

**បាត់សាកសព**

កំពុងតែចាក់សោចូលផ្ទះ ថានឹងប្រះសម្រាកក្រោយងូតទឹកបន្តិច ព្រោះក្ដៅខ្លួនរឿងប្រុសស្អាតស្រាប់តែហេ្សដាខល។

«កូនស្រី! មកកន្លែង វេជ្ជបណ្ឌិត Bozeman បន្ទាន់!»

«ខ្ញុំទៅហើយហេ្សដា លេខាគាត់នោះមិនចង់ទាំងស្ដីរកខ្ញុំផង!»

«មានរឿងហើយ សាកសពបាត់!»

«អូ អីគេហ្នឹង?» ខ្ញុំស្រែកដាក់ទូរសព្ទព្រោះភ្ញាក់ផ្អើលយ៉ាងអស្ចារ្យនឹងដំណឹងនេះ។  ដោយមិនបានសូម្បីផ្សើមទឹកមួយក្រេបណា ខ្ញុំស្ទុះទៅបើកឡានរីយ៉ៃលាន់ដឺ តម្រង់ទីតាំងការិយាល័យវេជ្ជបណ្ឌិត Bozeman និងលេខាដ៏គួរឱ្យធុញទ្រាន់របស់គាត់។

ចុះពីឡានភ្លាម ខ្ញុំឃើញចៅហ្វាយរបស់ខ្ញុំមកដល់មុនខ្ញុំបន្តិច ហើយបានរុញប៉ូលិសពីរនាក់ទៀតចេញពីផ្លូវរបស់គាត់។

«សាកសពបានបាត់ទៅហើយទាន»

«លាមកមែន»

គាត់រអ៊ូ។

ខ្ញុំនៅឈរភាំងក្បែរនោះស្ដាប់របាយការណ៍៖

«នៅពេលដែលដុកទ័រ Bozeman មកដល់ទីនេះ គ្មានសាកសពទេ។ បាត់តាំងពីយប់មិញយ៉ាង!»

លោកនាយជូតភ្នែកស្មុគខ្លាំង។ ខណៈកូនចៅគាត់រាយការណ៍ហើយដើរថយក្រោយ លោកនាយរអ៊ូ៖

«ថ្ងៃអន្សារបស់ខ្ញុំ»

«មានតែសពហ្នឹងចេះដើរ?» ខ្ញុំស្រែកទាំងកំហឹងនិងក្រឡេកមើលលេខាសំគិះកាលពីព្រឹកដែលធ្វើឈ្លើយប៉ោងខោដាក់ខ្ញុំ ហើយបញ្ជាក់ទៀត «ត្រូវ?»។

នាងធ្វើវាហី មិនអើពើនឹងកំហឹងរបស់ខ្ញុំទេ។ ខ្ញុំខ្ពើមដែរនឹងចំណាយពេលជាមួយមនុស្សធុនមិនទទួលខុសត្រូវនេះ។ ខ្ញុំផ្តោតត្រលប់ទៅរកលោកនាយ Clyde វិញ។

«ធ្វើម៉េចទៅទាន?»

«ម៉ំណេះ!» លោកនាយ Clyde បានហៅខ្ញុំឱ្យមកនៅឆ្ងាយពីអ្នកដទៃបន្តិចទើបគាត់ប្រាប់៖

«Jessie មានរឿងមួយ ស្តាប់ហើយកុំទាន់ផ្ទុះ!» ខ្ញុំគ្រវីក្បាល ទាំងត្រៀមនឹងអារម្មណ៍អាក្រក់ជាងនេះ។ លោកនាយខ្ញុំ និយាយបន្តដោយខ្សឹបៗ៖ «ខាង DNR (Department Of Natural Resources Division) កំពុងបញ្ជូនកងពិឃាតម្នាក់ទៅសម្លាប់ចចកហើយ!»

ខ្ញុំព្រិចភ្នែក ងក់ក្បាល។

«តែយើងមិនទាន់រកឃើញប្រភពពិត!» ខ្ញុំអធិប្បាយ។

«ខ្ញុំដឹង! តែខ្ញុំសុំទោស ខ្ញុំគ្មានជម្រើសទេ DNR សម្រេចចិត្តមិនសួរយើងឯណា ពួកគេកំពុងបញ្ជូនមនុស្សខ្លាំងៗទៅ! គេមិនទុកឱ្យយើងធ្វើការសិនទេ!»

«មនុស្សខ្លាំងៗម៉េចទៅ?» ខ្ញុំសួរឱ្យតែបានសួរ តែចិត្តខ្ញុំនឹកដល់សម្តីប្រុសស្អាត «ខ្ញុំនេះក៏ជាត្រកូលចចកដែរ!»

មេខ្ញុំឱនមកខ្សឹប៖

«ជាក្រុមស្វែងរកតាមប្រមាញ់ពិឃាតមិនដែលធ្លោយការណ៍! មកពីអាល្លឺម៉ង់ គេហៅថា ជាកងកម្លាំងពិសេសនៃអ្នកប្រមាញ់ចចកមិនដែលភ្លាត់»

«មិនដែលភ្លាត់?»

«ត្រូវ! ឥឡូវគេចង់ជួបនាង មុនពេលចេញបេសកកម្ម!»

តើពិតឬអ្វី? ខ្ញុំគាំង។

ប្រាំនាទីក្រោយមកខ្ញុំមកដល់នៅស្ថានីយ៍របស់កងកម្លាំងពិសេសនៃអ្នកប្រមាញ់ចចក។

ពួកគេនាំផ្លូវខ្ញុំទៅដល់បន្ទប់មួយមានបុរសម្នាក់ ពាក់ស្លាកថា  Mandenauer។ ជននេះសម្លឹងមកខ្ញុំដោយភ្នែកពណ៌ខៀវភ្លឺជ្រៅ។

ពេលខ្លះអាចថា គួរឱ្យខ្លាចព្រោះសឹងមិនឃើញប្រុស្រី។ គាត់មានកម្ពស់ខ្ពស់ តែរាងកាយស្គមសោះហ្នឹង គិតម៉េចហៅថា កងកម្លាំងពិសេសនៃអ្នកប្រមាញ់ចចក? ទោះយ៉ាងណាខ្ញុំសុភាពរាបសា៖

«ជំរាបសួរ! ខ្ញុំជេស៊ី ជាប៉ូលិស Johnston!»

កងកម្លាំងពិសេសនៃអ្នកប្រមាញ់ចចក លោក Mandenauer បន្តសម្លឹងមើលមកដោយមិនព្រមចាប់ដៃដែលខ្ញុំបោះទៅទេ។ រាក់ទាក់ពេកបានក្លាយទៅជាឆ្គង។ ខ្ញុំបន្ទាបដៃមកវិញ ហើយនិយាយទៀត៖

«ចាប់ផ្ដើមបាន!»

«ប្រាប់ខ្ញុំរឿងទាំងអស់មកម៉ាដាម! អ្នករងគ្រោះឡាសុន ចូលព្រៃដោយរបៀបណា ហើយម្ដេចបាននាងត្រូវបានខាំដោយចចក?»

គិតថា វែងណាស់នឹងប្រាប់។ តាមថា មានរបាយការណ៍លម្អិតហើយតើ! ខ្ញុំធុញនឹងធ្វើការបកក្រោយណាស់។ ខ្ញុំសំណូមពរ៖

«លោក....លោក Mandenauer ចង់ឱ្យខ្ញុំនាំទៅមើលកន្លែងកើតហេតុហ្មងទេ? យើងមើលបណ្ដើរនិយាយប្រាប់បណ្ដើរ»

«មិនទាន់ទេ ជួយនាំខ្ញុំទៅគ្លីនិកនោះសិនទៅ គ្លីនិកដែលអនុញ្ញាតឱ្យអ្នកគ្រូជំទង់ ឡាសុន ខាវ៉ែនចេញទៅបង្រៀនទាំងមិនទាន់ចាក់ថ្នាំបង្ការគ្រប់»។

ខ្ញុំលើកចិញ្ចើមតាមលំដាប់ព្រោះឆ្ងល់ជាន់ឆ្ងល់។

«please»

«ok»

ខ្ញុំបើកឡានទៀត។ បុរសនេះក្រឡេកមើលប្រើភ្នែកសស្វាចស្កេនជុំវិញទីក្រុងមិនរំលងសូម្បីដើមឈើមួយទេ។ គាត់ស្ងប់ស្ងៀមដូចសត្វក្ដាន់ តែម៉ត់ចត់ដូចតោ។

«នេះជាកន្លែងគាត់ ដុកទ័រ Bozeman អ្នកដែលបានមើលអ្នករងគ្រោះមុនគេ! កាលហ្នឹងយើងពិបាកទៅដល់ពេទ្យរដ្ឋពេក»

និយាយទាំងខ្ញុំនាំគាត់ចុះរលះរលាំង។ លោកនាយខ្ញុំ លោកClyde មិនទាន់ទៅណាទេ ដុកទ័រយ៉ាប់ម្នាក់នោះនិងលេខាគាត់ក៏នៅ។ ពួកគេក្រោកស្វាគមន៍អ្នកប្រមាញ់ចចក។ ស្រាប់តែបុរសដែលទើបនឹងមកដល់ជាមួយខ្ញុំនិយាយបំភ័យឡើង៖

«រឿងអាក្រក់មួយបានមកដល់ទីក្រុងនេះហើយ ត្រូវការវិធានការណ៍បន្ទាន់!»

លោកនាយមិនទាន់ថាអីផង ខ្ញុំលូកមាត់សួរបញ្ជាក់៖

«សុំច្បាស់ជាងនេះបន្តិច Mr.Mandenauer អាក្រក់យ៉ាងណា ហើយលោកចង់សំដៅលើវិធានការណ៍ដូចម្តេចខ្លះ?»

អ្នកប្រមាញ់មើលមកខ្ញុំ។

លោកនាយ Clyde ដែលដឹងថាខ្ញុំមានកាយវិការពុះកញ្ជ្រោលរហ័ស គាត់បានឈានជើងចូលមកពាំងរវាងយើងទាំងពីរ។

«តើយើងគួរធ្វើអ្វី?» លោកនាយសួរសុភាពនិងឱនមកច្បូតចង្ការង់ចាំស្តាប់ដោយអំណត់។

«មានមេរោគសាហាវមួយលើសពីឆ្កែឆ្កួត វាឆ្លងលឿន! តែ....កុំភ័យវិធានការណ៍ ព្រោះមានអ្នកប្រមាញ់ដ៏ល្អបំផុតម្នាក់នៅទីនេះជាមួយពួកលោក» Mandenauer ទះទ្រូងខ្លួនឯងអួតពេលនិយាយចប់។

ខ្ញុំបែរខ្នង តែនៅឮបុរសនេះអួតមកមិនចេះចប់៖

«ខ្ញុំនឹងសម្លាប់ពួកវាទាំងអស់ អាពួកសត្វដែលឆ្លងមេរោគ! ងាប់អស់អ្ហែង បានអ្វីដែលត្រូវព្រួយបារម្ភទៀត?»

«កុំតែសម្លាប់ដោយជនស៊ីវិល!» ខ្ញុំរអ៊ូរទាំរង៉ូវឌីឱ្យ Mandenauer រហូតគាត់ទុកដៃរបស់គាត់មកវិញឃឹតៗងាកមកចំហៀងខ្លួនសម្លឹងមកខ្ញុំដោយមិនចង់មើល។

ខ្ញុំញាក់ចិញ្ចើមផ្តើន៖

«មិនបាញ់ប្រជាជនទេមិនអ៊ីចឹង?»

«បាញ់! ប្រសិនបើនរណាម្នាក់ឆ្លង!»

ខ្ញុំបើកភ្នែកធំៗតវ៉ា៖

«ទេ ពួកគេនឹងប្រើវ៉ាក់សាំងការពារជំងឺឆ្កែឆ្កួត!»

«ប្រាប់ថាថ្នាំនោះជួយបានពីអង្កាល់?» Mandenauer ផ្ដើនខ្ញុំណាស់។

«លោកជាពេទ្យ?»

តាមបទពិសោធរបស់ខ្ញុំ រាល់ពេលដែលមាននរណាម្នាក់និយាយបែបនោះ វាឈឺចាប់។

ឃើញមិនស្រួល លោកនាយClyde របស់ខ្ញុំមកកៀកខ្ញុំចេញ ពីMandenauer ចូលជាមួយគាត់នៅក្នុងការិយាល័យរបស់ពេទ្យមួយក្បែរនោះ។ ពេលដែលគាត់បានបិទទ្វារជិតគាត់និយាយៈ

«Jessie នាងធ្វើបាបខ្ញុំ»

មិនច្បាស់ថាតើខ្ញុំគួរសុំទោស ឬសួរថាតើខ្ញុំបានធ្វើអ្វីខុស?

ហត់ណាស់គិតទៅតែនៅទ្រាំជានិច្ចជាមួយលោកនាយ។

«កុំធ្វើពើ ជេស៊ីឯងមានព័ត៌មានល្អនិងធ្ងន់ទាក់ទងរឿងនេះតែលាក់មិនប្រាប់ខ្ញុំទេ?»

«Clyde ខ្ញុំ?»

ភ្នែកខ្មៅរបស់គាត់ជ្រៅខ្លាំងដោយការខកចិត្ត ខ្ញុំឈប់មាត់លែងតវ៉ា។

«ខ្ញុំនិយាយពីករណី សាស្ត្រាចារ្យ William Cadotte! ហេតុអីនាងឱ្យរបស់នោះទៅគេ ទាំងមិននិយាយប្រាប់ខ្ញុំសិនជេស៊ី?»

ខ្ញុំងើបមុខវិញមួយរំពេច។

«Hell! ខ្ញុំគួរតែមិន Emotional ជាមួយបុរសអាក្រាតនោះដល់ថ្នាក់ត្រូវមេមកចោទសួរទេ!»។

ខ្ញុំនៅស្ងៀម លោកនាយស្រាប់តែឱនខ្សឹបៈ

«គាត់នោះមានបញ្ហា Jess! បញ្ហាធំ!»

ខ្ញុំបានក្រឡេកមើលក្នុងជម្រៅភ្នែកលោកនាយClyde ព្រោះរាល់ពេលដែលគាត់ហៅខ្ញុំថា Jess គាត់ពិតជាពិបាកចិត្តធ្ងន់ធ្ងរ។

«តែ....គាត់ជាអ្នកចេះសិល្បៈបុរាណ! ហើយហាក់ដូចជាគ្មានគ្រោះថ្នាក់អីផងសម្រាប់ខ្ញុំ» ។

«ប្រាកដម៉េះកូនឪ?»

លោកនាយ Clyde ថាហើយ ដើរចុះឡើងចច្រប់ក្នុងបន្ទប់ តានតឹង ញាប់ញ័រ។

«គេនោះជាមេក្លោងចចកកំណាច»

ខ្ញុំចងចិញ្ចើមហើយនិយាយតបៈ

«គេ....គេគ្រាន់តែជាមនុស្សអម្បូរបុរាណកាត់ឥណ្ឌា Ojibwe ដូចលោកនាយដែរ!»

«មិនដូចខ្ញុំទេ! ខ្ញុំជាអម្បូរ Lac du Flambeau ប្រុសម្នាក់នោះជាពួក Grand Portage! ខុសគ្នាដូចជនជាតិវេល និងអង់គ្លេស»។

«អូខេទាន!»

«នៅឱ្យឆ្ងាយពីមនុស្សនេះ Jess»

«Yes Sir ខ្ញុំនឹងធ្វើឱ្យអស់ពីសមត្ថភាព.....»

«តែ....នាងនឹងត្រូវជួបគេនោះម្តងទៀតសិន!»

«ព្រោះអីទាន?»

«ដើម្បីយកស្លាកនោះ ត្រលប់មកវិញ! វាល្ងង់ពេកទេបើអ្នកកាសែតដឹងថាប៉ូលិសស្រីឆ្នើមនៃខ្ញុំឱ្យភស្តុតាងធំដល់ទណ្ឌិតម្នាក់ ព្រោះតែគេជាប្រុសស្អាត?»

ខ្ញុំឈឺក្បាលម៉ោកយ៉ាងខ្លាំងដោយសារមានអារម្មណ៍ខ្មាសនឹងអារម្មណ៍ត្រូវគេ«ជេរ»។

«ខ្ញុំតាមពិតមានហេតុផលទាន ខ្ញុំកំពុងធ្វើការងារស្រាវជ្រាវប្រភពបន្ទះនោះលោកនាយ Clyde»

គាត់ដឹងថាខ្ញុំខឹងនៅពេលដែលហៅគាត់បែបនេះទាំងងារទាំងឈ្មោះ។

«នាងដឹងដែរជេស៊ី? ម្នាក់ William Cadotte នោះត្រូវបានគេចាប់មិនតិចដងទេ នាងដឹង?»

«ចាប់ខ្លួនដោយសារទោសអ្វីទាន!»

«រំខានសន្តិភាព ញុះញង់ឱ្យមានកុបកម្ម»

«ខ្ញុំមិនមែនជាប៉ូលិសបូករឿងទេ!»

ខ្ញុំតបធ្វើហី ធ្វើឱ្យលោកនាយចាប់ផ្តើមសង្ស័យពីមនោសញ្ចេតនាខ្ញុំនឹងប្រុសស្អាត។ គាត់សម្លឹងខ្ញុំមុតហើយទម្លាក់សំឡេងទាបៈ

«ការសេពគប់ជាមួយអ្នកបង្កើតបញ្ហាម្នាក់នោះ មិនធ្វើឱ្យអាជីពរបស់នាងប្រសើរឡើងទេជេស៊ី»

បេះដូងរបស់ខ្ញុំបានបញ្ចេញសំឡេងឈឺដ៏មុតស្រួចមួយ ឈឹប។

អ្វីដែលខ្ញុំមានជានិច្ចសម្រាប់បេះដូងសរសៃសសូងនេះ គឺការងាររបស់ខ្ញុំ ហើយខ្ញុំចូលចិត្តគុណតម្លៃនៃភាពជាអ្នកការពារសន្តិសុខ។

«លោកនាយកំពុងគំរាមកំហែងខ្ញុំ រឿងតួនាទី?»

«ទេ! មិនទាន់ឡើយ គ្រាន់តែផ្តល់ដំបូន្មាន មុនពេលអ្នកត្រូវទៅយកស្លាកនោះមកវិញ»

ខ្ញុំឡិងឡង់ភ្នែកសម្លឹងមេខ្ញុំ។ គាត់បន្ថែមយ៉ាងម៉ឺងម៉ាត់៖

«ឥឡូវជេស៊ី! ទៅយកឥឡូវ!»

ខ្ញុំបានធ្វើការគោរពតាមបែបយោធា បន្ទាប់មកចុចកែងជើង ហើយបំបែរខ្លួនដើរចេញពីការិយាល័យរ៉ុយ។